**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តី នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៤

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 29-Jul-2014, 10:29
CMS/CFO: Ly Bunloung

---

## បញ្ជីឯកសារបឋមសម្រាប់សំណុំរឿង ០០២/០២

---

**<u>ដាក់ដោយ</u>**

**ក្រុមមេធាវីការពារក្តី នួន ជា:**

សុន អរុណ
Victor KOPPE
សួន វិសាល
លីវ សុវណ្ណា
ព្រុំ ផល្លា
Doreen CHEN
Xiaoyang NIE

**<u>ចម្លងជូន</u>**

**សហចៅក្រមជាប់ចោទ**

**សហព្រះរាជអាជ្ញា:**

ជា លាង
Nicholas KOUMJIAN

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**

ពេជ អង្គ
Marie GUIRAUD

## I. សេចក្តីផ្តើម

១. សហមេធាវីការពារក្តី នួន ជា ("មេធាវីការពារក្តី") សូមដាក់ជូននូវបញ្ជីឯកសារបឋមដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ ("បញ្ជីឯកសារបឋម") ដែលមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ក ដោយស្នើសុំចាត់ថ្នាក់ជាឯកសារសាធារណៈ។ មេធាវីការពារក្តីសូមលើកឡើងនូវសារណានានាដូចខាងក្រោមពាក់ព័ន្ធនឹងបញ្ជីឯកសារបឋម។

## II. សារណា

### ក. ឯកសារទាំងនេះអាចទទួលយកបានតាមច្បាប់កម្ពុជាជាធរមានត្រឹមត្រូវ

២. មេធាវីការពារក្តីសូមរក្សានូវជំហររបស់ខ្លួនមិនផ្លាស់ប្តូរថា តាមច្បាប់ជាធរមានត្រឹមត្រូវ ពុំមាន "លក្ខខណ្ឌតម្រូវឲ្យជូនដំណឹងជាមុន" ដែលគ្រប់គ្រងការទទួលយកភស្តុតាងជាឯកសារនៅ អ.វ.ត.ក ទេ[1]។ ផ្ទុយទៅវិញ បញ្ជីឯកសារបឋមនេះ និងភស្តុតាងជាឯកសារបន្ថែមដែលបានស្នើឡើងដោយមេធាវីការពារក្តី គឺអាចទទួលយកបាន នៅក្នុងពេលវេលាណាមួយរហូតដល់ចុងសវនាការក្នុងសំណុំរឿង ០០២/០២។

៣. ដើម្បីអះអាងថាថ្មី និងធ្វើសេចក្តីសង្ខេបនៃគោលជំហររបស់ខ្លួន មេធាវីការពារក្តីសូមលើកឡើងដោយត្រួសៗថា នៅក្នុងមាត្រា ១២ នៃកិច្ចព្រមព្រៀងបង្កើត អ.វ.ត.ក នីតិវិធីនៅ អ.វ.ត.ក "ត្រូវស្របទៅតាមច្បាប់កម្ពុជា" លុះត្រាតែច្បាប់កម្ពុជាមិនបានចែង ចែងមិនច្បាស់លាស់ ឬមិនស្របទៅនឹងបទដ្ឋានអន្តរជាតិទៅលើបញ្ហាជាក់លាក់ណាមួយ[2]។ មាត្រា ៣៣៤ នៃ*ក្រមនីតិវិធីព្រហ្មទណ្ឌ* **(CCP)** កម្ពុជាចែងថា ជនជាប់ចោទមានសិទ្ធិដាក់ភស្តុតាងសង្ខេប "*រហូតដល់ចប់សវនាការសួរដេញដោល*"[3]។ បទប្បញ្ញត្តិនេះនៅក្នុងច្បាប់កម្ពុជាចែងជាក់លាក់ ច្បាស់លាស់ និងស្របទៅនឹងបទដ្ឋានអន្តរជាតិ។ ហេតុនេះ មេធាវីការពារក្តីសូមលើកឡើងថា មាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌមានអានុភាពលើវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ដើម្បីគ្រប់គ្រងការទទួលយកភស្តុតាង

---

[1] *សូមមើល ឧទាហរណ៍* ឯកសារលេខ **E131/1/13** "បញ្ជីឯកសារដែលត្រូវដាក់នៅដំណាក់កាលដំបូងនៃការជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង" ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ កថាខណ្ឌ ៥។

[2] *កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ* ចុះថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៣ កថាខណ្ឌ ១២។

[3] *ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា* ឆ្នាំ ២០០៧ មាត្រា ៣៣៤ (គូសបញ្ជាក់បន្ថែម)។

ជាឯកសារនៅ អ.វ.ត.ក។

៤. ហេតុនេះលក្ខណៈវិនិច្ឆ័យនានាចំពោះភស្តុតាងជាឯកសារគួរតែត្រូវយកមកវាយតម្លៃដើម្បីទទួលយក ត្រូវបានចែងមិនត្រឹមតែនៅក្នុងវិធាន ៨៧(៣) និង (៤) នៃវិធានផ្ទៃក្នុងប៉ុណ្ណោះទេ តែក៏មានចែងក្នុងមាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែរ ដែលអនុញ្ញាតឲ្យជនជាប់ចោទដាក់ "ឯកសារ និងភស្តុតាងទាំងអស់ដែលខ្លួនគិតថាមានប្រយោជន៍ក្នុងការស្វែងរកការពិត"។ ឯកសារភាគច្រើននៅក្នុងបញ្ជីឯកសារបឋមពាក់ព័ន្ធនឹងខ្លឹមសារសំខាន់នៃការការពារក្តីលោក នួន ជា៖ ដែលថា ព្រឹត្តិការណ៍នានានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺជាប្រតិកម្មទៅនឹងការឈ្លានពានដាក់ស្តែងទៅលើមួយផ្នែកនៃប្រទេសវៀតណាម និង វត្តមាន និងសកម្មភាពបង្កអស្ថិរភាពរបស់ភាគីដែលគាំទ្រដោយវៀតណាមនៅក្នុងជួរថ្នាក់ដឹកនាំនៃបក្សកុម្មុយនីស្តកម្ពុជា។ ឯកសារផ្សេងទៀតបង្ហាញពីភាពមិនប្រក្រតីនៃនីតិវិធីនៅ អ.វ.ត.ក ដែលរំលោភដល់សិទ្ធិជាសារវ័ន្តរបស់លោក នួន ជា ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ហើយហេតុនេះគឺសិទ្ធិស្វែងរកការពិត។ ជាសង្ខេប មេធាវីការពារក្តីសូមលើកឡើងថា រាល់ឯកសារទាំងអស់ដែលមាននៅក្នុងបញ្ជីឯកសារបឋមរបស់ខ្លួនគឺនាំទៅរកការបង្ហាញការពិតក្នុងសំណុំរឿង ០០២/០២ ហេតុនេះហើយ ឯកសារទាំងនោះអាចទទួលយកបាន។

**ខ. ជាជម្រើសម្យ៉ាងទៀត ឯកសារទាំងនោះអាចទទួលយកបានដោយស្វ័យប្រវត្តិ និងមិនមែនជាកម្មវត្ថុនៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងទេ**

៥. ជាជម្រើសម្យ៉ាងទៀត មេធាវីការពារក្តីប្រកាន់យកជំហរ រួមជាមួយភាគីទាំងអស់ក្នុងសំណុំរឿង ០០២/០២ អនុលោមតាមសំអាងហេតុនានាដែលបានលើកឡើងជូនអង្គជំនុំជម្រះរួមមកហើយថា វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងគួរអនុវត្ត "តែចំពោះភស្តុតាងដែលស្នើឡើងថ្មីៗដោយភាគីណាមួយ *បន្ទាប់ពីការបើកសវនាការជំនុំជម្រះក្តី* គឺថានៅក្រោយពេលសវនាការបឋមនាពេលខាងមុខនេះតែប៉ុណ្ណោះ"[4]។ ហេតុនេះ មេធាវីការពារក្តីសូមលើកឡើងថា ពុំចាំបាច់ដាក់បញ្ជីឯកសារបឋមអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងទេ ហើយហេតុនេះ ក៏ពុំចាំបាច់ត្រូវបង្ហាញថា ត្រូវតែស្របទៅនឹងលក្ខណៈវិនិច្ឆ័យដែលពាក់ព័ន្ធសម្រាប់ការទទួលយកឯកសារដែរ។ ផ្ទុយទៅវិញ ដោយសារបញ្ជីឯកសារបឋមត្រូវបានដាក់នៅពេលសវនាការបឋមក្នុងសំណុំរឿង ០០២/០២ នោះ រាល់

[4] ឯកសារលេខ E307 "សំណើរួមរបស់ភាគីសុំការបំភ្លឺអំពីការអនុវត្តវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង នៅក្នុងសំណុំរឿង ០០២/០២" ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៤ កថាខណ្ឌ ១៤(ខ) (គូសបញ្ជាក់បន្ថែម)។

ឯកសារទាំងអស់ដែលបានដាក់នៅក្នុងបញ្ជីឯកសារនេះអាចទទួលយកបានដោយស្វ័យប្រវត្តិតែម្តង។

**គ. ទោះបីអនុវត្តវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងក៏ដោយ ក៏ឯកសារទាំងនេះស្របទៅនឹងលក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលយកឯកសារដែរ**

៦. ទោះបីមេធាវីការពារក្តីបានលើកឡើងថា វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងមិនអនុវត្តទាល់តែសោះ ឬយ៉ាងហោចណាស់ក៏មិនអនុវត្តរហូតក្រោយពេលមានសវនាការបឋមក៏ដោយ ក៏មេធាវីការពារក្តីកត់សម្គាល់ឃើញថា អង្គជំនុំជម្រះជ្រើសរើសតាមវិធីផ្សេងទៀត ហើយបានណែនាំឲ្យភាគីដាក់ឯកសារថ្មីៗទៅតាមសំណើដែលមានចែងក្នុងវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង[5]។ អនុលោមតាមការណែនាំនេះ និងជាជម្រើសម្យ៉ាងទៀត មេធាវីការពារក្តីសូមដាក់ជូននូវបញ្ជីឯកសារបឋមអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។ វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងចែងថា អង្គជំនុំជម្រះអាចទទួលយកឯកសារដែលបានដាក់ក្នុងអំឡុងពេលសវនាការបាន ក្នុងករណីដែលវាស្របទៅនឹងលក្ខណៈវិនិច្ឆ័យនានាដែលមានចែងក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង និងដែលភាគីមិនអាចរកបាននៅមុនពេល "បើកសវនាការ" ដែលអង្គជំនុំជម្រះធ្លាប់បានធ្វើរួចមកហើយនៅ ខែ មិថុនា ឆ្នាំ ២០១១[6]។ ក្នុងចំណោមឯកសារចំនួន ២២ នៅក្នុងបញ្ជីឯកសារបឋមរបស់មេធាវីការពារក្តី មានតែឯកសារលេខ ២១ និង ២២ ប៉ុណ្ណោះដែលភាគីអាចរកបាននៅមុនពេល "បើកសវនាការ"។ មេធាវីការពារក្តីសូមលើកឡើងថា ឯកសារទាំងនេះក៏ស្របទៅនឹងលក្ខណៈវិនិច្ឆ័យក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង និងអាចទទួលយកបាន ដោយសារវាមានភាពពាក់ព័ន្ធ និងមានលក្ខណៈពិសេស ត្រូវបានទទួលយក និងបញ្ចូលក្នុងសំណុំរឿងរួចហើយ សក្តិសមនឹងបង្ហាញពីភាពមិនប្រក្រតីនៅក្នុងនីតិវិធី និងការរំលោភបំពានទៅនឹងសិទ្ធិរបស់លោក នួន ជា ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ អាចអនុញ្ញាតបានតាមផ្លូវច្បាប់ និងត្រូវបានដាក់ប្រកបដោយសុចរិតភាព។

៧. នៅពេលដែលភាគីអាចរកឯកសារបាននៅមុនពេលបើកសវនាការ អង្គជំនុំជម្រះបានអនុញ្ញាតឲ្យ

---

[5] ឯកសារលេខ **E307/1** "សេចក្តីសម្រេចលើសំណើរួមរបស់ភាគីសុំការបំភ្លឺអំពីការអនុវត្តវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (ឯកសារ E307) និងសេចក្តីជូនដំណឹងរបស់ក្រុមមេធាវីការពារក្តី នួន ជា ស្តីពីការមិនដាក់បញ្ជីភស្តុតាងដែលបានធ្វើបច្ចុប្បន្នភាព (ឯកសារ E305/3) ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៤ កថាខណ្ឌ ៥ ដល់ ៦ (គូសបញ្ជាក់បន្ថែម)។

[6] ឯកសារលេខ **E307/1** កថាខណ្ឌ ២។

ទទួលយកឯកសារទាំងនោះ “ដរាបណាផលប្រយោជន៍យុត្តិធម៌តម្រូវ ជាពិសេស ដរាបណាភស្តុតាងទាំងនេះជាភស្តុតាងដោះបន្ទុក ដែលតម្រូវឱ្យធ្វើការវាយតម្លៃដើម្បីជៀសវាងការសម្រេចសេចក្តីដោយអយុត្តិធម៌”[7] ឬនៅពេលដែលភស្តុតាង “ទាក់ទងជិតស្និទ្ធទៅនឹងឯកសារដែលមាននៅចំពោះមុខអង្គជំនុំជម្រះរួចហើយ និង ... ផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យវាយតម្លៃប្រភពទាំងនេះរួមគ្នា”[8]។ ពាក់ព័ន្ធនឹងឯកសារលេខ ១ ដល់ ២០ ក្នុងបញ្ជីឯកសារបឋមវិញ មេធាវីការពារក្តីសូមអះអាងសាជាថ្មីនូវសារណារបស់ខ្លួនក្នុងកថាខណ្ឌ ៤។ មេធាវីការពារក្តីសូមលើកឡើងបន្ថែមទៀតថា ឯកសារទាំងនោះនឹងជួយដោះបន្ទុកលោក នួន ជា ពាក់ព័ន្ធនឹងបទចោទនានាដែលមានរៀបរាប់ក្នុងឧបសម្ព័ន្ធ ក រួមទាំងដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងសម្ភារៈដែលមាននៅចំពោះមុខអង្គជំនុំជម្រះដែលមានលក្ខណៈដាក់បន្ទុកយ៉ាងមានសក្តានុពលរួចហើយ។ ហេតុនេះ ប្រយោជន៍យុត្តិធម៌ និងជាពិសេស ដោយសារមានភាពចាំបាច់ដើម្បីជៀសវាងការសម្រេចសេចក្តីដោយអយុត្តិធម៌នោះ តម្រូវឱ្យទទួលយកឯកសារនានាដែលមាននៅក្នុងបញ្ជីឯកសារបឋម។

## III. សេចក្តីសន្និដ្ឋាន

៨. សម្រាប់សំអាងហេតុនានាដែលបានលើកឡើងខាងលើ មេធាវីការពារក្តីសូមស្នើសុំឱ្យអង្គជំនុំជម្រះមេត្តាទទួលយកឯកសារនានាដែលបានយោងនៅក្នុងបញ្ជីឯកសារបឋមរបស់ខ្លួន នៅក្នុងឧបសម្ព័ន្ធ ក។

**សហមេធាវីការពារក្តី នួន ជា**

------------------ ------------------

**សុន អារុណ** **Victor KOPPE**

[7] ឯកសារលេខ **E307/1** កថាខណ្ឌ ៣ និង*សូមមើល* ឯកសារលេខ **E190** “សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត” ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ ៣៦។

[8] ឯកសារលេខ **E289/2** “សេចក្តីសម្រេចលើសំណើដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលសុំដាក់ភស្តុតាងថ្មីនៅចំពោះមុខអង្គជំនុំជម្រះ (ឯកសារ E289) និងចម្លើយតបរបស់ ខៀវ សំផន (ឯកសារ E289/1)” ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៣ កថាខណ្ឌ ៣។